អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
Victims Support Section
Section d'appui aux victimes

ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

នៅឆ្នាំនេះ អង្គភាពគាំពារជនរងគ្រោះ (អ.គ.ជ) បានរៀបចំវេទិកាថ្នាក់តំបន់លើកទីបីរបស់ខ្លួនសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី (ដ.រ) ក្នុងសំណុំរឿង ០០២ និងបានរៀបចំកិច្ចប្រជុំនៅសាលប្រជុំឆ្នេរទន្លេ ក្នុងខេត្តស្វាយរៀង សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី (ដ.រ) ចំនួន ៣០០ នាក់ ក្នុងសំណុំរឿង ០០២ ដែលអញ្ជើញមកពីភាគខាងកើតនៃទន្លេមេគង្គ រួមមាន៖ ព្រៃវែង កណ្តាល កំពង់ចាម និងស្វាយរៀង។ ក្នុងចំណោមសិក្ខាកាមទាំងនោះ ក៏មានមន្ត្រីសាធារណៈមកពីផ្នែកផ្សេងៗទៀតនៃសាលាក្តី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (CPLs) តំណាងមកពីអង្គការអន្តរការី (IOs) និងអភិបាលរងខេត្តស្វាយរៀងផងដែរ។

វេទិកានេះត្រូវបានរៀបចំឡើងពិសេសសម្រាប់ ដ.រ ដើម្បីលើកស្ទួយការយល់ដឹងរបស់ពួកគាត់ចំពោះយន្តការ និងមធ្យោបាយដែល ដ.រ អាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ ហើយក៏ដើម្បីផ្តល់ឱកាសឲ្យ ដ.រ បានជួបជាមួយមន្ត្រីតុលាការនៃ អ.វ.ត.ក និងមេធាវីរបស់ពួកគាត់ ដើម្បីទទួលបានការធ្វើបច្ចុប្បន្នភាពលើព័ត៌មានរបស់តុលាការនេះ។

នៅមុនថ្ងៃបើកវេទិកានេះ ដ.រ ត្រូវបានអញ្ជើញឲ្យទៅទស្សនារូបសំណាកស្ថិតនៅក្នុងវត្តធ្លក ដែលនៅទីនេះប្រជាជនចំនួន ១.៥០០ នាក់ ត្រូវបានគេយកមកសម្លាប់នៅក្នុងសម័យខ្មែរក្រហម។ ទីតាំងរម្លឹកការចងចាំនេះត្រូវបានកសាងឡើងដើម្បីរម្លឹកដល់វិញ្ញាណក្ខន្ធរបស់ជនរងគ្រោះ ដែលបានស្លាប់នៅក្នុងសម័យនោះ។

បន្ទាប់មក ដ.រ ត្រូវបានអញ្ជើញឲ្យទៅទស្សនាខ្សែភាពយន្តឯកសារស្តីពីការស្វែងរកការពិត និងយុត្តិធម៌ ដែលត្រូវបានរៀបចំដោយផ្នែកកិច្ចការសាធារណៈរបស់ អ.វ.ត.ក។

នៅថ្ងៃបន្ទាប់ វេទិកានេះបានចាប់ផ្តើមនៅពេលព្រឹក ដោយមានការចាក់ភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា មុនពិធីសូត្រមន្តបង្សុកូលតាមបែបព្រះពុទ្ធសាសនាដោយព្រះសង្ឃចំនួន ៥ អង្គ ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម។ ព្រឹត្តិការណ៍នេះត្រូវបានអញ្ជើញចូលរួមពីសំណាក់លោក រង ឈឿង ប្រធាន អ.គ.ជ, លោក សោម សុជាតិ អភិបាលរងខេត្តស្វាយរៀង, លោកជំទាវ ជា លាង សហព្រះរាជអាជ្ញាជាតិនៃ អ.វ.ត.ក, លោក William Smith សហព្រះរាជអាជ្ញារងអន្តរជាតិនៃ អ.វ.ត.ក, លោក ញ៉ែម សំណាង មន្ត្រីមកពីអង្គភាពគាំពារសាក្សី/អ្នកជំនាញ (WESU), លោក តាន់ វិសាល អ្នកគ្រប់គ្រងគម្រោងនៃ អ.គ.ជ, លោក ឡុង ខេត (LONG Khet) នាយកប្រតិបត្តិនៃអង្គការយុវជនដើម្បីសន្តិភាព (អ.យ.ស), លោក ឡាត់ ឃី អ្នកសម្របសម្រួលកម្មវិធីនៃសាលាក្តីខ្មែរក្រហមប្រចាំអង្គការ ADHOC, លោក ជី ធារិទ្ធ តំណាងមកពីអង្គការ DC-Cam , លោកបណ្ឌិត មុន្នី សុធារ៉ា អ្នកសម្របសម្រួលរបស់អង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO), លោក នេត្រ ផល្លី និងលោកស្រី ហាវ សុភា ដែលជា ដ.រ ក្នុងសំណុំរឿង ០០១, លោក ពេជ្រ អង្គ សហេធាវីនាំមុខជាតិ និងលោកស្រី Elisabeth Simonneau Fort សហេធាវីនាំមុខអន្តរជាតិ។

លោក រង ឈឿង បានស្វាគមន៍សិក្ខាកាមទាំងអស់ និងបានជំរុញឲ្យមានការចូលរួមរបស់ជនរងគ្រោះ ដោយលើកទឹកចិត្តពួកគាត់ឲ្យឆក់យកឱកាសនេះ ដើម្បីបញ្ជាក់អំពីការព្រួយបារម្ភ ឬបញ្ហាណាមួយ ហើយក៏បានធ្វើបច្ចុប្បន្នភាពជូនពួកគាត់អំពីស្ថានភាពបច្ចុប្បន្ននៃសាលក្រមរបស់ ឌុច ដែលនឹងចេញនៅក្នុងមីនា ឆ្នាំ២០១១ នេះ។ លោក ឈឿង ក៏បានបង្ហាញណែនាំឲ្យស្គាល់អភិបាលរងខេត្តស្វាយរៀង ដែលបានចែករំលែកបទពិសោធន៍ជាច្រើនរបស់គាត់នៅក្នុងសម័យខ្មែរក្រហម ហើយគាត់មានអារម្មណ៍ថា តុលាការនេះបានរួមចំណែកដល់ការរំពឹងទុករបស់គាត់ ក្នុងការទទួលបានយុត្តិធម៌ ទោះបីគាត់មិនមែនជា ដ.រ ក៏ដោយ។ នៅក្នុងចំណោមវាគ្មិន លោក រាជ សម្បត្តិ បានបញ្ជាក់ដល់សិក្ខាកាមថា បណ្តឹងសាទុក្ខរបស់ ឌុច នឹងចាប់ផ្តើមដាក់ជូននៅក្នុងខែមីនា ហើយទោះបីជាមានការផ្តន្ទាទោសបែបណាក្តី ក៏គាត់នឹងស្ថិតនៅក្នុងមន្ទីរឃុំឃាំងយូរទៅទៀត។ ទាំងលោកស្រី ជា លាង និងលោក William Smith បាននិយាយថា ការិយាល័យសហព្រះរាជអាជ្ញា ដែលមានបុគ្គលិកមកពីប្រទេសផ្សេងៗ កំពុងតែធ្វើការងារយ៉ាងលំបាក និងយ៉ាងមានប្រសិទ្ធភាព ដើម្បីសម្រេចឲ្យបានយុត្តិធម៌ជូនជនរងគ្រោះរាប់លាននាក់ នៅក្រោមប្រព័ន្ធច្បាប់ស៊ីវិលរបស់កម្ពុជា និងដើម្បីធានាឲ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ សហមេធាវីនាំមុខជាតិ និងអន្តរជាតិតំណាងដើមប

ណ្ដឹងរដ្ឋប្បវេណី លោក ពេជ្រ អង្គ និងលោកស្រី Elisabeth Simonneau Fort បានថ្លែងអំពីតួនាទី និងការទទួលខុសត្រូវនៃផ្នែករបស់ពួកគាត់ពាក់ព័ន្ធនឹង ដ.រ។

ថ្មីៗនេះ វេទិកាថ្នាក់តំបន់ប្រភេទនេះ បានសម្រួលដល់ការចូលរួមពីសំណាក់ ដ.រ ចំនួន ១.០៥០ នាក់ មកពី ១៥ ខេត្ត។ វេទិកាថ្នាក់តំបន់ជាសកម្មភាពមួយ ក្នុងចំណោមសកម្មភាពផ្សព្វផ្សាយ ដែលឧបត្ថម្ភថវិកាដោយការិយាល័យការបរទេសរបស់ប្រទេសអាល្លឺម៉ង់ តាមរយៈទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិ (GIZ)។ អ.គ.ជ នឹងរៀបចំឲ្យមានវេទិកាថ្នាក់តំបន់ថែមទៀត នៅកន្លែងផ្សេងទៀតនៅក្នុងប្រទេស មុននឹងការជំនុំជម្រះលើសំណុំរឿង ០០២ ចាប់ផ្ដើមដំណើរការក្រោយមកទៀតក្នុងឆ្នាំ ២០១១ ដើម្បីអនុញ្ញាតឲ្យ ដ.រ របស់យើង ចំនួន ២.០០០ នាក់ ជួបជាមួយតំណាងផ្លូវច្បាប់របស់ខ្លួន។

---

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក អ៊ឹម សុភាព

អ្នកសម្របសម្រួលកម្មវិធីផ្សព្វផ្សាយ

អង្គភាពគាំពារជនរងគ្រោះ, អ.វ.ត.ក

ទូរសព្ទដៃលេខ: +៨៥៥ (០) ៧៧ ៧៧៧ ៣៦៧

ទូរសព្ទលើតុលេខ: +៨៥៥ (០) ២៣ ២១៩ ៨១៤ ext. ៦៦០២

អ៊ីមែល: im.sophea@eccc.gov.kh